ឧបត្ថម្ភការបោះពុម្ពដោយកម្មវិធី GIZ/EU-SPACE

“ការលើកកម្ពស់ការបំពេញការងារ គណនេយ្យភាព និងការចូលរួមរបស់ប្រជាពលរដ្ឋ”

កិច្ចសហប្រតិបត្តិការ អាល្លឺម៉ង់
DEUTSCHE ZUSAMMENARBEIT

Implemented by giz Deutsche Gesellschaft für Internationale Zusammenarbeit (GIZ) GmbH

## រាជរដ្ឋាភិបាលកម្ពុជា

### គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

# ១. អនុក្រឹត្យ ស្តីពីដំណើរការផ្ទេរ មុខងារ និងធនធានដល់រដ្ឋបាលថ្នាក់ក្រោមជាតិ

# និង

# ២.សេចក្តីណែនាំស្តីពី បញ្ជីវិភាគ មុខងារ និង ការពិនិត្យមើលមុខងារឡើងវិញ

លេខាធិការដ្ឋាន គ.ជ.អ.ប

ខែកក្កដា ឆ្នាំ២០១៣

# អារម្ភកថា

ក្នុងគោលបំណងអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងជំរុញដល់ដំណើរការនៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិឱ្យកាន់តែស៊ីជម្រៅថែមទៀត នៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១២ រាជរដ្ឋាភិបាលបានអនុម័តដាក់ឱ្យប្រើប្រាស់ អនុក្រឹត្យស្តីពីដំណើរការទូទៅនៃការផ្ទេរមុខងារ និងធនធានឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។ លេខាធិការដ្ឋាន គ.ជ.អ.ប ដោយមានកិច្ចសហការបច្ចេកទេសពីដៃគូអភិវឌ្ឍដូចជា ធនាគារអភិវឌ្ឍអាស៊ី (ADB) អង្គការUNICEF និងកម្មវិធីសហភាពអឺរ៉ុបដើម្បីលើកកម្ពស់ការបំពេញការងារគណនេយ្យភាព និងការចូលរួមរបស់ប្រជាពលរដ្ឋ (SPACE) អនុវត្តដោយ GIZ បានរៀបចំ និងដាក់ឱ្យប្រើប្រាស់នូវសេចក្តីណែនាំស្តីពីការរៀបចំបញ្ជីវិភាគមុខងារ សម្រាប់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាព និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ នៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១២ និង សេចក្តីណែនាំស្តីពីការពិនិត្យមើលមុខងារឡើងវិញ សម្រាប់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាព និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៣ ។

ដោយពិនិត្យឃើញ ពីភាពចាំបាច់នៃសេចក្តីណែនាំទាំងពីរនេះ លេខាធិការដ្ឋាន គ.ជ.អ.ប ដោយមានការចូលរួម សហការឧបត្ថម្ភគាំទ្រថវិកាពីកម្មវិធីកម្មវិធីសហភាពអឺរ៉ុបដើម្បីលើកកម្ពស់ការបំពេញការងារគណនេយ្យភាព និង ការចូលរួមរបស់ប្រជាពលរដ្ឋ (SPACE) អនុវត្តដោយ GIZ បានរៀបចំចងក្រង និងបោះពុម្ពកម្រង អនុក្រឹត្យលេខ ៦៨ អនក្រ.បក ស្តីពីដំណើរការទូទៅនៃការផ្ទេរមុខងារនិងធនធានឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ និងសេចក្តីណែនាំទាំងពីរខាងលើ សម្រាប់ជាជំនួយស្មារតីដល់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា អាជ្ញាធរគ្រប់លំដាប់ថ្នាក់ និងអ្នកពាក់ព័ន្ធ ដើម្បីយកទៅប្រើប្រាស់តាមតម្រូវការជាក់ស្តែង។

លេខាធិការដ្ឋាន គ.ជ.អ.ប សង្ឃឹម កម្រងឯកសារនេះ នឹងជួយសម្រួលដល់ការបំពេញការងាររបស់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា អាជ្ញាធរគ្រប់លំដាប់ថ្នាក់ និងអ្នកពាក់ព័ន្ធទាំងអស់ក្នុងដំណើរការនៃការរៀបចំបញ្ជីវិភាគមុខងារនិងការពិនិត្យមើលមុខងារឡើងវិញ ដើម្បីឱ្យការអនុវត្តនូវកិច្ចដំណើរការផ្ទេរមុខងារ និង ធនធាននានាពី ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា អាជ្ញាធរគ្រប់លំដាប់ថ្នាក់ ឱ្យទៅដល់ថ្នាក់ក្រោមជាតិទទួលបានជោគជ័យ ក្នុងគោលដៅរួមចំណែកដល់ការអនុវត្តគោលនយោបាយកំណែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិ ការលើកកម្ពស់ប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ បន្តជំរុញការអភិវឌ្ឍ និងការកាត់បន្ថយភាពក្រីក្រ ។

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៣

**សេចក្តីផ្តើម**

កំណែទម្រង់នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ បានចាប់ផ្តើមឡើងដោយក្រុមប្រឹក្សាដែលកើតឡើងពីការបោះឆ្នោតនៅគ្រប់កម្រិតរដ្ឋបាលថ្នាក់ក្រោមជាតិ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ក្នុងនោះរួមមានៈ ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ និងសង្កាត់ ។ ក្រុមប្រឹក្សាទាំងនេះត្រូវមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋក្នុងការពង្រឹងសុខុមាលភាពរបស់ប្រជាពលរដ្ឋ ព្រមទាំងចូលរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រតាមរយៈការពង្រឹងនូវការផ្តល់សេវា ការគ្រប់គ្រងធនធានធម្មជាតិ និងការបង្កើននូវ ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានក៏ដូចជាឱកាសការងារ ។

កំណែទម្រង់នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ធ្វើឡើងក្នុងន័យជំរុញអភិបាលកិច្ចតាមរយៈការបង្វិតរដ្ឋបាលទៅជិតប្រជាពលរដ្ឋដែលអាចឱ្យក្រុមប្រឹក្សាយល់ដឹងបានកាន់តែប្រសើរ និងអាចឆ្លើយតបទៅតាមតម្រូវការរបស់មូលដ្ឋាន ហើយដែលប្រជាពលរដ្ឋអាចបង្កើនការចូលរួមកាន់តែច្រើនជាមួយរដ្ឋបាលរបស់ខ្លួន។

ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ គឺតម្រូវឱ្យមានការផ្ទេរមុខងារនិងធនធាន ពីថ្នាក់ជាតិ ទៅឱ្យក្រុមប្រឹក្សាដែលបានជាប់ឆ្នោត ដើម្បីឱ្យក្រុមប្រឹក្សាទាំងនេះអាចបំពេញនូវការទទួលខុសត្រូវដ៏សំខាន់ក្នុងការធ្វើសេចក្តីសម្រេច អំពីបញ្ហាដែលមានផលប៉ះពាល់ទៅដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ។ រាល់សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាត្រូវធ្វើឡើងនៅក្នុងគោលដៅបម្រើផលប្រយោជន៍សាធារណៈ ព្រមទាំងឆ្លើយតបទៅនឹងតម្រូវការមូលដ្ឋាន ។ ការរៀបចំបញ្ជីវិភាគមុខងារ និងកិច្ចដំណើរការនៃការពិនិត្យមើលមុខងារឡើងវិញគឺជាដំណើរការដែលត្រូវសម្រេចថាមុខងារ និងធនធានណាដែលនឹងត្រូវផ្ទេរទៅឱ្យក្រុមប្រឹក្សា ។ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ គឺជាស្ថាប័នដែលត្រូវទទួលខុសត្រូវពិនិត្យមើលនូវកិច្ចដំណើរការទាំងនេះ។

ការរៀបចំបញ្ជីវិភាគមុខងារ គឺជាដំណាក់កាលដំបូងហើយដែលពាក់ព័ន្ធទៅនឹងការកំណត់ (ការវិភាគផ្គូរផ្គង) មុខងារនិងធនធានតាមវិស័យ រាប់ទាំងធនធានហិរញ្ញវត្ថុ បុគ្គលិក និងទ្រព្យសម្បត្តិ ជាដើម។ ការរៀបចំបញ្ជីវិភាគមុខងារធ្វើឡើងដើម្បីធានាថាសេចក្តីសម្រេចប្រកបដោយព័ត៌មាននេះ អាចត្រូវបានធ្វើឡើងក្នុងកំឡុងពេលនៃកិច្ចដំណើរការនៃការពិនិត្យមើលមុខងារឡើងវិញ។

កិច្ចដំណើរការនៃការពិនិត្យមើលមុខងារឡើងវិញ គឺជាដំណើរការនៃការវិភាគលើវិស័យណាមួយរបស់រដ្ឋាភិបាលក្នុងគោលដៅកំណត់មុខងារ និងធនធានដែលត្រូវផ្ទេរទៅឱ្យក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ ។ តាមរយៈការ

ប្រើប្រាស់នូវលក្ខណៈវិនិច្ឆ័យ កិច្ចដំណើរការនៃការពិនិត្យមើលមុខងារឡើងវិញនឹងពិនិត្យមើលទៅលើការផ្ទេរផ្គូង មុខងារ ដើម្បីកំណត់ថាតើមុខងារណាខ្លះដែលត្រូវផ្ទេរទៅឱ្យក្រុមប្រឹក្សាកម្រិតណាមួយ ដោយភ្ជាប់ជាមួយនូវធនធានដែលចាំបាច់នានា។

នៅពេលដែលការសម្រេចពីការផ្ទេរមុខងារ ទៅឱ្យក្រុមប្រឹក្សានៅកម្រិតណាមួយ ដំណើរការនៃការពិនិត្យមើលមុខងារឡើងវិញ នឹងកំណត់ថាតើមុខងារណាខ្លះជាមុខងារជាកាតព្វកិច្ច ឬជាមុខងារជាជម្រើស ។ កិច្ចដំណើរការនេះក៏ពាក់ព័ន្ធផងដែរទៅនឹងការសម្រេចថា តើមុខងារនោះគួរតែត្រូវបានប្រគល់ឱ្យក្លាយជាមុខងារផ្ទាល់របស់ក្រុមប្រឹក្សាឬជាមុខងារដែលត្រូវធ្វើប្រតិភូកម្ម ។ បន្ថែមពីលើនេះទៀត កិច្ចដំណើរការនៃការពិនិត្យមើលមុខងារឡើងវិញក៏កំណត់ផងដែរថាតើធនធាន និងការអភិវឌ្ឍសមត្ថភាពណាខ្លះដែលតម្រូវឱ្យមាននៅពេលផ្ទេរមុខងារ។

កម្រងឯកសារនេះរួមមានអនុក្រឹត្យ និងសេចក្តីណែនាំសំខាន់ៗពីរផ្សេងទៀតដែលទាក់ទងទៅនឹងការរៀបចំបញ្ជីវិភាគមុខងារ និងកិច្ចដំណើរការនៃការពិនិត្យមើលមុខងារឡើងវិញៈ

- អនុក្រឹត្យ លេខ៦៨ អនក្រ.បក ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១២ ស្តីពី ដំណើរការទូទៅនៃការផ្ទេរមុខងារ និងធនធានឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ
- សេចក្តីណែនាំ របស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ស្តីពីការរៀបចំបញ្ជីវិភាគមុខងាររបស់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា និងអាជ្ញាធរ គ្រប់លំដាប់ថ្នាក់
- សេចក្តីណែនាំ របស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ស្តីពីកិច្ចដំណើរការនៃការពិនិត្យមើលមុខងារឡើងវិញរបស់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាព និងអាជ្ញាធរ គ្រប់លំដាប់ថ្នាក់

អនុក្រឹត្យលេខ ៦៨ ត្រូវបានដាក់ឱ្យប្រើដើម្បីបំពេញបន្ថែមនូវក្របខ័ណ្ឌច្បាប់សម្រាប់ការរៀបចំបញ្ជីវិភាគមុខងារ និងកិច្ចដំណើរការនៃការពិនិត្យមើលមុខងារឡើងវិញ ។ ដោយឡែកសេចក្តីណែនាំស្តីពីការរៀបចំបញ្ជីវិភាគមុខងារ និងការពិនិត្យមើលមុខងារឡើងវិញត្រូវបានរៀបចំឡើងដោយលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ជាឧបករណ៍បច្ចេកទេសសម្រាប់បណ្តាក្រសួង ស្ថាប័នដើម្បីយកមកប្រើប្រាស់នៅពេលរៀបចំបញ្ជីវិភាគមុខងារ និងការពិនិត្យមើលមុខងារឡើងវិញក្នុងគោលដៅការផ្ទេរមុខងារ និងធនធានទៅឱ្យក្រុមប្រឹក្សា។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៦៨ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ដំណើរការទូទៅនៃការផ្ទេរមុខងារនិងធនធានឲ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

- បានឃើញអនុក្រឹត្យលេខ២៣ អនក្រ.បក ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ២៣៤ អនក្រ.បក ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១១ ស្តីពីការកែសម្រួលមាត្រា៤ មាត្រា៧ មាត្រា៨ មាត្រា១២ មាត្រា១៣ មាត្រា១៥ មាត្រា១៦ និងមាត្រា១៧ នៃអនុក្រឹត្យលេខ២៣ អនក្រ.បក ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១២

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលបំណងធានានូវការផ្ទេរមុខងារនិងធនធាននានាពីក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ឲ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយមានលក្ខណៈជាប្រព័ន្ធតាមដំណាក់កាល មានសនិទានភាព ការសម្របសម្រួល ការពិគ្រោះយោបល់ តម្លាភាព និងប្រកបដោយសមធម៌ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈនិងការអភិវឌ្ឍ។

**មាត្រា ២.-**

អនុក្រឹត្យនេះមានគោលដៅកំណត់អំពីដំណើរការទូទៅនិងពេលវេលានៃការរៀបចំផ្ទេរមុខងារនិងធនធានឲ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។

**មាត្រា ៣.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះការផ្ទេរមុខងារនិងធនធាននានាពីក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ឲ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងរវាងរដ្ឋបាលថ្នាក់ក្រោមជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា ៤.-**

វាក្យសព្ទបច្ចេកទេសនៅក្នុងអនុក្រឹត្យនេះមានន័យដូចតទៅ៖

- **មុខងារ** សំដៅដល់អំពើឬសកម្មភាពដែលរាប់បញ្ចូលទាំងការផ្តល់សេវាសាធារណៈ ហេដ្ឋារចនាសម្ព័ន្ធ និងមធ្យោបាយផ្សេងៗទៀត។

- **ធនធាន** សំដៅដល់ទ្រព្យសម្បត្តិ ហិរញ្ញវត្ថុ ចំណូល បុគ្គលិក និងសមត្ថភាព។
- **ក្រុមប្រឹក្សា** សំដៅដល់ ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ក្រុមប្រឹក្សាឃុំ និងក្រុមប្រឹក្សាសង្កាត់។
- **ទ្រព្យសម្បត្តិ** សំដៅដល់គ្រឿងម៉ាស៊ីន យានយន្ត ឧបករណ៍ គ្រឿងសង្ហារិម សម្ភារៈ ការិយាល័យ លិខិតស្នាម ឯកសារ និងដីសាធារណៈ អចលនទ្រព្យសាធារណៈ សំណង់សាធារណៈ ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ដូចជា ស្ពាន អគារ ព្រែក ផ្លូវ ឬវត្ថុប្រហាក់ប្រហែលគ្នានេះ។
- **រដ្ឋបាលថ្នាក់ក្រោមជាតិ** សំដៅដល់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។
- **មុខងារជាកាតព្វកិច្ច** សំដៅដល់មុខងារដែលត្រូវបានគ្រប់គ្រង ចាត់ចែង និងអនុវត្តដោយរដ្ឋបាលថ្នាក់ក្រោមជាតិអនុលោមទៅតាមបទដ្ឋាននិងនីតិវិធីដែលកំណត់ដោយច្បាប់ ឬព្រះរាជក្រឹត្យ ឬអនុក្រឹត្យ ឬលិខិតបទដ្ឋានគតិយុត្តនានា។
- **មុខងារជាជម្រើស** សំដៅដល់មុខងារដែលមិនមានលក្ខណៈជាកាតព្វកិច្ច ហើយរដ្ឋបាលថ្នាក់ក្រោមជាតិអាចជ្រើសរើសអនុវត្តឬមិនអនុវត្ត។
- **ផ្ទេរ** សំដៅដល់ការប្រគល់ឬការធ្វើប្រតិភូកម្មមុខងារ។
- **ការប្រគល់មុខងារ** សំដៅដល់ការផ្ទេរភាពជាម្ចាស់នៃមុខងារ ការទទួលខុសត្រូវ អំណាច និងធន្ទានុសិទ្ធិទាំងអស់ដែលចាំបាច់ដើម្បីគ្រប់គ្រងនិងអនុវត្តមុខងារ។
- **ប្រតិភូកម្មមុខងារ** សំដៅដល់ការផ្ទេរនូវមុខងារ ការទទួលខុសត្រូវ អំណាច និងធន្ទានុសិទ្ធិដើម្បីគ្រប់គ្រងនិងអនុវត្តមុខងារក្នុងនាមអាជ្ញាធរដែលធ្វើប្រតិភូកម្ម ដោយផ្អែកតាមតម្រូវការនៃការធ្វើប្រតិភូកម្មនោះ។ អាជ្ញាធរដែលបានធ្វើប្រតិភូកម្មនៅតែរក្សាភាពជាម្ចាស់លើកិច្ចការដែលបានធ្វើប្រតិភូកម្ម។
- **ការផ្ទេរដែលមានលក្ខណៈជាប្រព័ន្ធ** សំដៅដល់ការផ្ទេរមុខងារដែលត្រូវភ្ជាប់មកជាមួយនូវការផ្ទេរធនធានសមស្រប។

## ជំពូកទី២
## ដំណើរការទូទៅនៃការផ្ទេរមុខងារនិងធនធាន
## ផ្នែកទី១
## គោលការណ៍

**មាត្រា ៥.-**

ការផ្ទេរមុខងារនិងធនធានឲ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវធ្វើឡើងជាដំណាក់កាល មានសនិទានភាព លក្ខណៈជាប្រព័ន្ធ ការសម្របសម្រួល ការពិគ្រោះយោបល់ ផែនការ តម្លាភាព និងប្រកបដោយសមធម៌។

**មាត្រា ៦.-**

ការពិនិត្យមើលមុខងារឡើងវិញ ត្រូវផ្ដល់អាទិភាពចំពោះកិច្ចការចាំបាច់ដែលជះឥទ្ធិពលដោយផ្ទាល់ដល់ការកាត់បន្ថយភាពក្រីក្រ ការកែលម្អគុណភាពនៃជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងការអភិវឌ្ឍមូលដ្ឋាន។

**មាត្រា ៧.-**

ការផ្ទេរមុខងារតាមរយៈការប្រគល់ឬការធ្វើប្រតិភូកម្ម ត្រូវធ្វើឡើងដោយផ្អែកលើគោលការណ៍ដូចខាងក្រោម៖

- ស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា
- អាចគ្រប់គ្រងនិងអនុវត្តបានប្រកបដោយប្រសិទ្ធភាពនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា
- បម្រើឬផ្ដល់ផលប្រយោជន៍ជាចម្បងដល់ប្រជាជននៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា និង
- មានផលប៉ះពាល់ជាចម្បងនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា។

ការផ្ទេរមុខងារតាមរយៈការប្រគល់ឬការធ្វើប្រតិភូកម្ម ត្រូវធ្វើឡើងដោយធានាថា៖

- ការផ្ទេរមុខងារត្រូវផ្សារភ្ជាប់ជាមួយការផ្ទេរធនធានហិរញ្ញវត្ថុ ធនធានមនុស្ស និងធនធានផ្សេងទៀតដែលចាំបាច់និងសមស្រប
- មានតម្លាភាព ការពិគ្រោះយោបល់ និងការចូលរួមពីក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា អាជ្ញាធរគ្រប់លំដាប់ថ្នាក់ និងតំណាងនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលទទួលមុខងារ ដោយមានការសម្របសម្រួលពីគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ សរសេរជាអក្សរកាត់ថា "**គ.ជ.អ.ប.**" អនុគណៈកម្មាធិការមុខងារនិងធនធាន និងលេខាធិការដ្ឋាន **គ.ជ.អ.ប.** និង
- មានការរំខានជាអប្បបរមាទៅលើប្រតិបត្តិការដែលកំពុងដំណើរការរបស់រាជរដ្ឋាភិបាល។

**មាត្រា ៨.-**

**គ.ជ.អ.ប.** ត្រូវពិនិត្យមើលឡើងវិញនូវការទទួលខុសត្រូវនិងមុខងាររបស់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដើម្បីកំណត់មុខងារនិងធនធានសម្រាប់ផ្ទេរឲ្យទៅដល់រដ្ឋបាលនៅថ្នាក់ក្រោមជាតិ។

**មាត្រា ៩.-**

**គ.ជ.អ.ប.** ដោយមានជំនួយពីអនុគណៈកម្មាធិការមុខងារនិងធនធាន និងលេខាធិការដ្ឋាន **គ.ជ.អ.ប.** ត្រូវដឹកនាំសម្របសម្រួល គាំទ្រ និងតាមដានកិច្ចដំណើរការផ្ទេរមុខងារនិងធនធានដែលអនុវត្តដោយក្រសួង ស្ថាប័ន មន្ទីរ អង្គភាព និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ក្នុងស្មារតីទទួលខុសត្រូវខ្ពស់។

## ផ្នែកទី២
## ការរៀបចំបញ្ជីវិភាគមុខងារ

**មាត្រា ១០.-**

ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ត្រូវរៀបចំបញ្ជីវិភាគមុខងារ ដើម្បីកំណត់ពី៖

- មុខងារទាំងអស់ដែលកំពុងអនុវត្តជាក់ស្តែងនិងអង្គភាពដែលគ្រប់គ្រងនិងទទួលខុសត្រូវលើការអនុវត្តមុខងារទាំងនេះ ដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ក្របខ័ណ្ឌច្បាប់ជាមូលដ្ឋានសម្រាប់បំពេញមុខងារទាំងនេះ
- ធនធានហិរញ្ញវត្ថុជាក់ស្តែងនាពេលបច្ចុប្បន្នដែលបានប្រើប្រាស់ដើម្បីអនុវត្តមុខងារទាំងនេះ
- ធនធានមនុស្សជាក់ស្តែងនាពេលបច្ចុប្បន្នដែលទទួលខុសត្រូវក្នុងការអនុវត្តមុខងារទាំងនេះ និង
- មធ្យោបាយ សម្ភារៈ បរិក្ខារ និងធនធានផ្សេងទៀតដែលចាំបាច់សម្រាប់អនុវត្តមុខងារទាំងនេះ។

**មាត្រា ១១.-**

**គ.ជ.អ.ប.** ត្រូវចេញសេចក្តីណែនាំស្តីពីការរៀបចំបញ្ជីវិភាគមុខងារ សម្រាប់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ធ្វើជាមូលដ្ឋានក្នុងការរៀបចំបញ្ជីវិភាគមុខងាររបស់ខ្លួន។

បន្ទាប់ពីបានរៀបចំបញ្ជីវិភាគមុខងាររបស់ខ្លួន ក្រសួង ស្ថាប័នត្រូវធ្វើរបាយការណ៍ស្តីពីការរៀបចំបញ្ជីវិភាគមុខងារនេះ ជូន **គ.ជ.អ.ប.** ដើម្បីពិនិត្យនិងសម្រេច។

## ផ្នែកទី៣
## ការពិនិត្យមើលមុខងារឡើងវិញ

**មាត្រា ១២.-**

បន្ទាប់ពីទទួលបានការឯកភាពពី **គ.ជ.អ.ប.** លើរបាយការណ៍ស្តីពីការរៀបចំបញ្ជីវិភាគមុខងារ ក្រសួង ស្ថាប័ន ត្រូវពិនិត្យមើលឡើងវិញនូវមុខងារ ធនធាន លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ និងការទទួលខុសត្រូវក្នុងការអនុវត្តមុខងារ ដើម្បីកំណត់អំពីមុខងារ និងធនធាន ដែលត្រូវផ្ទេរឲ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា ១៣.-**

ការពិនិត្យមើលមុខងារឡើងវិញ ត្រូវធ្វើឡើងស្របទៅនឹង៖

- មាត្រា២១៥ដល់មាត្រា២២១នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- របាយការណ៍ស្តីពីការរៀបចំបញ្ជីវិភាគមុខងារដែលបានឯកភាពដោយ **គ.ជ.អ.ប.**
- គោលការណ៍នានាដែលមានចែងនៅក្នុងមាត្រា៥ មាត្រា៦ និងមាត្រា៧នៃអនុក្រឹត្យនេះ និង
- សេចក្តីសម្រេចនិងសេចក្តីណែនាំនានារបស់ **គ.ជ.អ.ប.**។

**មាត្រា ១៤.-**

**គ.ជ.អ.ប.** និងក្រសួង ស្ថាប័ននានាត្រូវធានាឲ្យមានសង្គតិភាពក្នុងការពិនិត្យមើលមុខងារឡើងវិញនៅក្នុងវិស័យទាំងឡាយណាដែលមានការពាក់ព័ន្ធនឹងក្រសួង ស្ថាប័នលើសពីមួយ និងត្រូវពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នទាំងនេះ ព្រមទាំងជាមួយនឹងអ្នកពាក់ព័ន្ធនៅថ្នាក់ជាតិនិងនៅថ្នាក់ក្រោមជាតិនានាផ្សេងទៀត។

**មាត្រា ១៥.-**

នៅពេលដែលមុខងារណាមួយ ត្រូវផ្ទេរឲ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិនោះ ដំណើរការពិនិត្យមើលមុខងារឡើងវិញក៏ត្រូវកំណត់ផងដែរពីធនធានដែលត្រូវផ្ទេរជាមួយនឹងមុខងារ ព្រមជាមួយនឹងផែនការអភិវឌ្ឍន៍សមត្ថភាព ដែលអាចជាតម្រូវការចាំបាច់ដើម្បីធានាដល់ការចាត់ចែង ការគ្រប់គ្រង និងការអនុវត្តមុខងារនិងធនធានទាំងនោះ។

**មាត្រា ១៦.-**

ក្រសួង ស្ថាប័ននានាត្រូវកំណត់អំពីតួនាទីនិងការទទួលខុសត្រូវរបស់ខ្លួន បន្ទាប់ពីមុខងារត្រូវបានផ្ទេរ។

ការកំណត់អំពីតួនាទីនិងការទទួលខុសត្រូវរបស់ខ្លួនទាំងនេះ រួមមានការអភិវឌ្ឍក្របខ័ណ្ឌគោលនយោបាយ ការរៀបចំបទដ្ឋាន ការគ្រប់គ្រង ការតាមដានត្រួតពិនិត្យ ព្រមទាំងការកំណត់ពីតម្រូវការនៃការអភិវឌ្ឍសមត្ថភាពនានាដែលពាក់ព័ន្ធនឹងតួនាទីនិងការទទួលខុសត្រូវទាំងនេះ។

**មាត្រា ១៧.-**

**គ.ជ.អ.ប.** ត្រូវចេញសេចក្ដីណែនាំស្ដីពីការពិនិត្យមើលមុខងារឡើងវិញសម្រាប់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ធ្វើជាមូលដ្ឋានក្នុងការពិនិត្យមើលមុខងាររបស់ខ្លួនឡើងវិញ។

បន្ទាប់ពីបានពិនិត្យមើលឡើងវិញនូវមុខងាររបស់ខ្លួន ក្រសួង ស្ថាប័នត្រូវធ្វើរបាយការណ៍ស្ដីពីការពិនិត្យមើលមុខងារឡើងវិញ ព្រមទាំងផែនការអភិវឌ្ឍន៍សមត្ថភាពនានាជូន **គ.ជ.អ.ប.** ដើម្បីពិនិត្យនិងសម្រេច។

## ផ្នែកទី៤
## ការអភិវឌ្ឍសមត្ថភាពដើម្បីទទួលមុខងារនិងធនធាន

**មាត្រា ១៨.-**

ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ត្រូវទទួលខុសត្រូវក្នុងការអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារនិងធនធានក្នុងពេលវេលាមួយសមស្រប ដោយស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ **គ.ជ.អ.ប.** ស្របតាមមាត្រា២៣៥នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

**មាត្រា ១៩.-**

ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ត្រូវរៀបចំផែនការអភិវឌ្ឍន៍សមត្ថភាព ដើម្បីឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិដែលទទួលបាននូវមុខងារ មានសមត្ថភាពក្នុងការគ្រប់គ្រង

ចាត់ចែង និងអនុវត្តមុខងារនិងធនធានទាំងនោះឲ្យបានស្មើឬលើសកម្រិតបទដ្ឋានដែលមាននាពេលបច្ចុប្បន្ន។

**មាត្រា ២០.-**

ការរៀបចំផែនការអភិវឌ្ឍន៍សមត្ថភាពទាំងនេះ ត្រូវធ្វើឡើងដោយមានកិច្ចសហការ និងមានការពិគ្រោះយោបល់រវាងក្រសួងស្ថាប័នថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ។

## ផ្នែកទី៥
## ការផ្ទេរមុខងារ ធនធានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិ

**មាត្រា ២១.-**

ការប្រគល់មុខងារឬការធ្វើប្រតិភូកម្មមុខងារ ត្រូវធ្វើឡើងដោយច្បាប់ ឬព្រះរាជក្រឹត្យ ឬអនុក្រឹត្យ ឬប្រកាស ឬលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ស្របតាមមាត្រា២៣៨នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

**មាត្រា ២២.-**

ការផ្ទេរមុខងារឲ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវធ្វើឡើងស្របតាមមាត្រា២៣៣ ដល់មាត្រា២៤០នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

ការផ្ទេរធនធានហិរញ្ញវត្ថុសម្រាប់ការអនុវត្តមុខងារដែលត្រូវផ្ទេរឲ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវធ្វើឡើងស្របតាមបទប្បញ្ញត្តិដែលមានចែងនៅក្នុងជំពូកទី៥ ផ្នែកទី៦នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងជំពូកទី៣ ផ្នែកទី២នៃច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

ការផ្ទេរទ្រព្យសម្បត្តិសម្រាប់ការអនុវត្តមុខងារដែលត្រូវផ្ទេរឲ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវធ្វើឡើងស្របតាមបទប្បញ្ញត្តិដែលមានចែងនៅក្នុងជំពូកទី៥ ផ្នែកទី៧នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងស្របតាមបទប្បញ្ញត្តិដែលមានចែងនៅក្នុងជំពូកទី៤នៃច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា ២៣.-**

**គ.ជ.អ.ប**. ត្រូវពិនិត្យមើលសេចក្តីព្រាងច្បាប់ សេចក្តីព្រាងព្រះរាជក្រឹត្យ សេចក្តីព្រាងអនុក្រឹត្យ និងសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតដែលកំណត់អំពីការផ្ទេរមុខងារនិងធនធានឲ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាថាសេចក្តីព្រាងច្បាប់ សេចក្តីព្រាងព្រះរាជក្រឹត្យ សេចក្តីព្រាងអនុក្រឹត្យ និងសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តទាំងនេះ ស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងអនុក្រឹត្យនេះ។

**មាត្រា ២៤.-**

ការផ្ទេរមុខងារឲ្យទៅដល់ឃុំ សង្កាត់ ត្រូវលើកលែងចំពោះវិស័យទាំងឡាយដូចមានចែងនៅក្នុងមាត្រា៤៥នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។

ការផ្ទេរមុខងារឲ្យទៅដល់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវលើកលែងចំពោះវិស័យនិងមុខងារទាំងឡាយដែលត្រូវបានបម្រុងទុកផ្តាច់មុខសម្រាប់ក្រសួង ស្ថាប័ននៅថ្នាក់ជាតិ។

**មាត្រា ២៥.-**

ដំណើរការនិងនីតិវិធីនៃការផ្ទេរធនធានហិរញ្ញវត្ថុសម្រាប់អនុវត្តមុខងារដែលត្រូវផ្ទេរ ត្រូវកំណត់ដោយច្បាប់ ឬព្រះរាជក្រឹត្យ ឬអនុក្រឹត្យ ឬប្រកាសស្តីពីការផ្ទេរមុខងារនោះ។

## ផ្នែកទី៦

## ស្ថាប័នទទួលបន្ទុកអនុវត្ត

**មាត្រា ២៦.-**

**គ.ជ.អ.ប.** ដោយមានជំនួយពីអនុគណៈកម្មាធិការមុខងារនិងធនធាន និងលេខាធិការដ្ឋាន **គ.ជ.អ.ប.** ទទួលខុសត្រូវរួមចំពោះរាជរដ្ឋាភិបាលលើដំណើរការពិនិត្យមើលឡើងវិញនូវមុខងារនិងដំណើរការផ្ទេរមុខងារនិងធនធានស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

**គ.ជ.អ.ប.** ត្រូវធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាល ស្តីពីវឌ្ឍនភាពនៃដំណើរការពិនិត្យមើលឡើងវិញនូវមុខងារនិងការផ្ទេរមុខងារនិងធនធាន។

ក្រសួង ស្ថាប័នដែលអនុវត្តការផ្ទេរមុខងារនិងធនធាន ត្រូវធ្វើរបាយការណ៍ស្តីពីវឌ្ឍនភាពនៃដំណើរការនៃការអនុវត្តការផ្ទេរមុខងារនិងធនធានរបស់ខ្លួនជូន **គ.ជ.អ.ប.**។

**មាត្រា ២៧.-**

ក្រសួង ស្ថាប័ន ត្រូវទទួលខុសត្រូវជាចម្បងចំពោះ **គ.ជ.អ.ប.** លើដំណើរការរៀបចំបញ្ជីវិភាគមុខងារ ការពិនិត្យមើលឡើងវិញនូវមុខងារ និងដំណើរការផ្ទេរមុខងារនិងធនធាន។

**មាត្រា ២៨.-**

រដ្ឋបាលនៅថ្នាក់ក្រោមជាតិ ត្រូវទទួលខុសត្រូវក្នុងការចូលរួមចំណែកជួយគាំទ្រដល់ដំណើរការពិនិត្យមើលឡើងវិញនូវមុខងារដែលត្រូវផ្ទេរឲ្យទៅដល់រដ្ឋបាលរបស់ខ្លួន។

**មាត្រា ២៩.-**

រដ្ឋបាលរាជធានីនិងរដ្ឋបាលក្រុង ត្រូវពិនិត្យមើលមុខងាររបស់ខ្លួនឡើងវិញស្របតាមគោលការណ៍ដែលមានចែងនៅក្នុងមាត្រា៥ មាត្រា៦ និងមាត្រា៧នៃអនុក្រឹត្យនេះ ដើម្បីកំណត់អំពីមុខងារដែលអាចធ្វើប្រតិភូកម្មឲ្យទៅដល់រដ្ឋបាលខណ្ឌនិងរដ្ឋបាលសង្កាត់ ដោយមានភ្ជាប់ជាមួយនឹងការផ្ទេរធនធានសមស្រប។

## ផ្នែកទី៧

## យន្តការគាំទ្រ

**មាត្រា ៣០.-**

**គ.ជ.អ.ប.** ត្រូវធានាថា ការផ្ទេរមុខងារនិងធនធានត្រូវបានធ្វើឡើងតាមលក្ខណៈជាប្រព័ន្ធ តាមដំណាក់កាល មានសនិទានភាព ការសម្របសម្រួល ការពិគ្រោះយោបល់ តម្លាភាព និងប្រកបដោយសមធម៌។

**មាត្រា ៣១.-**

អនុគណៈកម្មាធិការមុខងារនិងធនធាន មានភារកិច្ចជួយលើការងារសម្របសម្រួល ពិគ្រោះយោបល់ ព្រមទាំងផ្តល់អនុសាសន៍ដល់ **គ.ជ.អ.ប.** លើការងារទាំងអស់ដែលពាក់ព័ន្ធនឹងភារកិច្ចនិងការទទួលខុសត្រូវរបស់ **គ.ជ.អ.ប.** ក្នុងការកំណត់និងការផ្ទេរមុខងារនិងធនធានឲ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។

លេខាធិការដ្ឋាន **គ.ជ.អ.ប.** ទទួលខុសត្រូវក្នុងការជួយអនុគណៈកម្មាធិការមុខងារនិងធនធាន និង **គ.ជ.អ.ប.** ផ្នែកបច្ចេកទេស ការសម្របសម្រួល ការពិគ្រោះយោបល់ ព្រមទាំងការគាំទ្រផ្នែកហិរញ្ញវត្ថុដល់ដំណើរការផ្ទេរមុខងារនេះ។

## ជំពូកទី៣

## អន្តរប្បញ្ញត្តិ

### ផ្នែកទី១

### ដំណើរការផ្ទេរមុខងារនិងធនធានសម្រាប់វិស័យឬកិច្ចការអាទិភាព

**មាត្រា ៣២.-**

នៅដំណាក់កាលពីឆ្នាំ២០១២ដល់ឆ្នាំ២០១៣ **គ.ជ.អ.ប.** ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ត្រូវផ្តល់អាទិភាពដល់ដំណើរការផ្ទេរមុខងារក្នុងវិស័យឬកិច្ចការមួយចំនួនដូចខាងក្រោម៖

- កសិកម្ម
- អប់រំ
- ព្រៃឈើ ជលផល ធនធានធម្មជាតិ និងបរិស្ថាន
- សុខាភិបាល អាហារូបត្ថម្ភ និងសេវាប្រជាជន រួមទាំងតម្រូវការផ្សេងៗរបស់ស្ត្រី បុរស យុវវ័យ កុមារ ជនងាយរងគ្រោះ និងជនជាតិដើមភាគតិច
- ឧស្សាហកម្មនិងការគាំទ្រការអភិវឌ្ឍសេដ្ឋកិច្ច
- ការប្រើប្រាស់ដីធ្លី
- ការងារសុរិយោដីនិងការងារសំណង់
- ការផលិតនិងការចែកចាយអគ្គិសនី
- ការគ្រប់គ្រងទឹក
- តម្រូវការពិសេសឬតម្រូវការដែលបានកំណត់ជាក់លាក់សម្រាប់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ដោយគិតទាំងវិស័យទេសចរណ៍ តំបន់ប្រវត្តិសាស្ត្រ និងកេរដំណែលវប្បធម៌ផងដែរ
- សង្គមកិច្ច
- អភិវឌ្ឍន៍ជនបទ

ព្រមទាំងត្រូវយកចិត្តទុកដាក់ផ្តល់ការគាំទ្រលើផ្នែកហេដ្ឋារចនាសម្ព័ន្ធ មធ្យោបាយ និងសម្ភារៈចាំបាច់ដើម្បីចាត់ចែងការទទួលខុសត្រូវលើមុខងារដែលបានប្រគល់និងធ្វើប្រតិភូកម្មខាងលើនេះ។

**មាត្រា ៣៣.-**

ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ដែលទទួលខុសត្រូវលើមុខងារដែលស្ថិតនៅក្នុងចំណោមវិស័យឬកិច្ចការអាទិភាពដែលបានកំណត់ក្នុងមាត្រា៣២ខាងលើនេះ ត្រូវបញ្ចប់ការធ្វើបញ្ជីវិភាគមុខងារនិងការពិនិត្យមើលមុខងារឡើងវិញ ហើយដាក់របាយការណ៍ស្តីពីការធ្វើបញ្ជីវិភាគមុខងារនិងរបាយការណ៍ស្តីពីការពិនិត្យមើលមុខងារឡើងវិញទាំងនោះជូន **គ.ជ.អ.ប.** ដើម្បីពិនិត្យនិងសម្រេចយ៉ាងយូរនៅចុងឆ្នាំ២០១២។

ចំពោះក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ដែលពាក់ព័ន្ធនឹងវិស័យឬកិច្ចការអាទិភាពខាងលើត្រូវអនុវត្តដំណើរការផ្ទេរមុខងារ ដោយភ្ជាប់ជាមួយការផ្ទេរធនធានហិរញ្ញវត្ថុ ធនធានមនុស្ស និងធនធានផ្សេងទៀតដែលចាំបាច់និងសមស្របទៅតាមដំណាក់កាលៗ យ៉ាងយូរនៅក្នុងឆ្នាំ២០១៣ បន្ទាប់ពីទទួលបានការឯកភាពពី **គ.ជ.អ.ប.** លើរបាយការណ៍ស្តីពីការធ្វើបញ្ជីវិភាគមុខងារ និងរបាយការណ៍ស្តីពីការពិនិត្យមើលមុខងារឡើងវិញរបស់ខ្លួន។

**មាត្រា ៣៤.-**

ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ដែលមិនស្ថិតនៅក្នុងវិស័យឬកិច្ចការអាទិភាពខាងលើ ត្រូវអនុវត្តទៅតាមដំណើរការរៀបចំធ្វើបញ្ជីវិភាគមុខងារនិងការពិនិត្យមើលឡើងវិញនូវមុខងារដូចគ្នានឹងក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ដែលស្ថិតនៅក្នុងវិស័យឬកិច្ចការអាទិភាពដែរ និងដាក់ជូន **គ.ជ.អ.ប.** នូវរបាយការណ៍ស្តីពីការធ្វើបញ្ជីវិភាគមុខងារ និងការពិនិត្យមើលមុខងារឡើងវិញសម្រាប់ការផ្ទេរមុខងារ យ៉ាងយូរនៅក្នុងឆ្នាំ២០១៣។

**មាត្រា ៣៥.-**

ពេលវេលា ដំណាក់កាលនីមួយៗ និងក្រសួង ស្ថាប័ន មន្ទីរ អង្គភាព និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ដែលត្រូវចាប់ផ្តើមអនុវត្តដំណើរការផ្ទេរមុខងារនិងធនធាន ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ **គ.ជ.អ.ប.**។

## ផ្នែកទី២
## ការផ្ទេរធនធានមនុស្ស

**មាត្រា ៣៦.-**

ក្នុងអំឡុងពេលដែលមិនទាន់មានច្បាប់ឬបទប្បញ្ញត្តិស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ដំណើរការ និងនីតិវិធីនៃការផ្ទេរធនធានមនុស្សសម្រាប់អនុវត្តមុខងារដែលបានផ្ទេរ ត្រូវកំណត់ដោយច្បាប់ ឬព្រះរាជក្រឹត្យ ឬអនុក្រឹត្យ ឬប្រកាសស្តីពីការផ្ទេរមុខងារនិងធនធាននោះ និងស្របតាមបទប្បញ្ញត្តិដែលមានចែងនៅក្នុងជំពូកទី៥ ផ្នែកទី៨នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

## ជំពូកទី៤
## អវសានប្បញ្ញត្តិ

**មាត្រា ៣៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣៨.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ២០១២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា៣៨*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*

រាជរដ្ឋាភិបាលកម្ពុជា

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

# សេចក្តីណែនាំ
# ស្តីពី
# ការរៀបចំបញ្ជីវិភាគមុខងាររបស់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់

ខែកញ្ញា ឆ្នាំ២០១២

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)

លេខ...១០៤...សសរ.../គ.ជ.អ.ប

រាជធានីភ្នំពេញ, ថ្ងៃទី..២៨.. ខែ..កញ្ញា.. ឆ្នាំ២០..១២

# សេចក្តីសម្រេច

## ស្តីពី

## ការដាក់ឲ្យប្រើប្រាស់នូវសេចក្តីណែនាំស្តីពីការរៀបចំបញ្ជីទ្រព្យសម្បត្តិរបស់ក្រសួង ស្ថាប័នមន្ទីរ អង្គភាពនានា និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់

## គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩០៨/១០៥៥ចុះថ្ងៃទី២៥ខែកញ្ញាឆ្នាំ២០០៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ចុះថ្ងៃទី២០ខែកក្កដាឆ្នាំ១៩៩៤ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/០៨ចុះថ្ងៃទី២៤ខែមករាឆ្នាំ១៩៩៦ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខនស/រកម/០៣០១/០៥ចុះថ្ងៃទី១៩ខែមីនាឆ្នាំ២០០១ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំសង្កាត់
- បានឃើញព្រះរាជក្រមលេខនស/រកម/០៥០៨/០១៧ចុះថ្ងៃទី២២ខែឧសភាឆ្នាំ២០០៨ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានីខេត្ត ក្រុងស្រុកខណ្ឌ
- បានឃើញព្រះរាជក្រមលេខនស/រកម/០៦១១/០១១ចុះថ្ងៃទី១៧ខែមិថុនាឆ្នាំ២០១១ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/១២០៨/១៤២៩ចុះថ្ងៃទី៣១ខែធ្នូឆ្នាំ២០០៨ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ២៣ អនក្រ.បក ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ២៣៤ អនក្រ.បក ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១១ ស្តីពីការកែសម្រួលមាត្រា៤ មាត្រា៧ មាត្រា៨ មាត្រា១២ មាត្រា១៣ មាត្រា១៥ មាត្រា១៦ និងមាត្រា១៧ នៃអនុ



មហាវិថីព្រះនរោត្តម: លេខាធិការដ្ឋាននៃគ.ជ.អ.ប ក្រសួងមហាផ្ទៃ ។ ទូរស័ព្ទ: (៨៥៥-២៣) ៧២០ ០៦១/ ៧២០ ០៣៨ E-mail: info@ncdd.gov.kh Website: www.ncdd.gov.kh
Norodom Blvd., National Committee for Sub-National Democratic Development Secretariat (NCDDS). Ministry of Interior. Tel: (855-23) 720 061 / 720 038

របស់លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

- បានឃើញអនុក្រឹត្យលេខ៣៦អនក្រ.បក ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃមូលនិធិក្រុង ស្រុក
- បានឃើញអនុក្រឹត្យលេខ៦៨អនក្រ.បក ចុះថ្ងៃទី១០ខែឧសភាឆ្នាំ២០១២ ស្តីពីដំណើរការទូទៅនៃការផ្ទេរមុខងារនិងធនធានឲ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានទទួលការឯកភាពពីគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ក្នុងកិច្ចប្រជុំលើកទី៧ នាថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១២។

## សម្រេច

### ប្រការ ១.–

ដាក់ឲ្យប្រើប្រាស់នូវ "**សេចក្តីណែនាំស្តីពីការរៀបចំបញ្ជីវិភាគមុខងាររបស់ក្រសួង ស្ថាប័នមន្ទីរ អង្គភាពនានា និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់**"។

### ប្រការ ២.–

ក្រសួង ស្ថាប័ន មន្ទីរអង្គភាពនានា និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ត្រូវប្រើប្រាស់សេចក្តីណែនាំនេះធ្វើជាមូលដ្ឋានក្នុងការរៀបចំបញ្ជីវិភាគមុខងាររបស់ខ្លួន ដូចបានកំណត់ក្នុងអនុក្រឹត្យលេខ៦៨អនក្រ.បក ចុះថ្ងៃទី១០ខែឧសភាឆ្នាំ២០១២ ស្តីពីដំណើរការទូទៅនៃការផ្ទេរមុខងារនិងធនធានឲ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។

### ប្រការ ៣.–

សេចក្តីសម្រេចនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**ជ.គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍ**
**តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ**
**ប្រធាន**

**ស ខេង**

**ចម្លងជូន៖**
- *ក្រសួង ស្ថាប័នសមាជិក គ.ជ.អ.ប*
- *ក្រសួង ស្ថាប័នពាក់ព័ន្ធ*
- *លេខាធិការដ្ឋាន គ.ជ.អ.ប*

*<u>"ដើម្បីអនុវត្ត"</u>*
- *ឯកសារកាលប្បវត្តិ*

# មាតិកា

ទំព័រ


| | | | |
|---|---|---|---|
| ១. | សេចក្តីផ្តើម | | ១ |
| ២. | មូលដ្ឋាននៃសេចក្តីណែនាំ | | ១ |
| ៣. | វិសាលភាពនៃសេចក្តីណែនាំ | | ២ |
| ៤. | វាក្យសព្ទបច្ចេកទេសដែលប្រើនៅក្នុងសេចក្តីណែនាំ | | ២ |
| ៥. | ដំណើរការរៀបចំបញ្ជីវិភាគមុខងារ | | ៣ |
| | **ជំហានទី១** : | ការរៀបចំ និងឯកភាពលើផែនការការងារសម្រាប់ការរៀបចំបញ្ជីវិភាគមុខងារ | ៥ |
| | **ជំហានទី២** : | ការស្រង់មុខងារដែលមានកំណត់នៅក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា | ៨ |
| | **ជំហានទី៣** : | ការពិនិត្យផ្ទៀងផ្ទាត់មុខងារដែលបានស្រង់ក្នុងជំហានទី២ជាមួយនឹងការអនុវត្តជាក់ស្តែង | ១០ |
| | **ជំហានទី៤** : | ការពិនិត្យផ្ទៀតផ្ទាត់បន្ថែមលើមុខងារដែលមានកំណត់នៅក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាជាមួយនឹងផែនការ និងយុទ្ធសាស្ត្រសំខាន់ៗរយៈពេលមធ្យម | ១៤ |
| | **ជំហានទី៥** : | ការបូកសរុបព័ត៌មានដែលប្រមូលបាននៅក្នុងជំហានទី២ដល់ជំហានទី៤ | ១៦ |
| | **ជំហានទី៦** : | ការប្រមូលព័ត៌មានអំពីការពង្រាយបុគ្គលិក និងផ្គូរផ្គងបុគ្គលិកទាំងនេះជាមួយនឹងមុខងារដែលកំណត់នៅក្នុងជំហានទី៥ | ១៨ |
| | **ជំហានទី៧** : | ការប្រមូលព័ត៌មានអំពីការវិភាជហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល និងផ្គូរផ្គងធនធានហិរញ្ញវត្ថុទាំងនេះជាមួយនឹងមុខងារដែលកំណត់នៅក្នុងជំហានទី៥ | ២៧ |
| | **ជំហានទី៨** : | ការប្រមូលព័ត៌មានអំពីការផ្តល់ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍ និងផ្គូរផ្គងធនធានហិរញ្ញវត្ថុទាំងនេះជាមួយនឹងមុខងារដែលបានកំណត់នៅក្នុងជំហានទី៥ | ៣២ |
| | **ជំហានទី៩** : | ការចងក្រងជាឯកសារនូវបទពិសោធន៍ពាក់ព័ន្ធនឹងវិមជ្ឈការនិងវិសហមជ្ឈការមុខងារ និងការចុះកិច្ចសន្យាជាមួយវិស័យឯកជន និងអង្គការសង្គមស៊ីវិល | ៣៥ |
| | **ជំហានទី១០** : | ការរៀបចំរបាយការណ៍ស្តីពីការវិភាគមុខងារ និងទទួលការឯកភាពពីក្រសួងស្ថាប័នចំពោះរបាយការណ៍រៀបចំបញ្ជីវិភាគមុខងារចុងក្រោយមុនដាក់ជូន គ.ជ.អ.ប | ៣៧ |

## ១. គោលបំណង

សេចក្តីណែនាំនេះត្រូវបានរៀបចំឡើងជាមគ្គុទ្ទេសក៍សម្រាប់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ក្នុងការរៀបចំបញ្ជីវិភាគមុខងារទាំងអស់ដែលកំពុងអនុវត្តជាក់ស្តែង និងអង្គភាពដែលគ្រប់គ្រងនិងទទួលខុសត្រូវលើការអនុវត្តមុខងារ ក្របខ័ណ្ឌច្បាប់ជាមូលដ្ឋានសម្រាប់បំពេញមុខងារ ធនធានហិរញ្ញវត្ថុ និងធនធានមនុស្សជាក់ស្តែងនាពេលបច្ចុប្បន្ន មធ្យោបាយ សម្ភារៈបរិក្ខារ និងធនធានផ្សេងទៀតដែលចាំបាច់ដើម្បីអនុវត្តមុខងារទាំងនេះ។

សេចក្តីណែនាំនេះកំណត់អំពីដំណើរការជាជំហាន១ ដើម្បីប្រមូលព័ត៌មានចាំបាច់សម្រាប់រៀបចំរបាយការណ៍ស្តីពីការរៀបចំបញ្ជីវិភាគមុខងាររបស់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់។ តាមរយៈការរៀបចំរបាយការណ៍អំពីការរៀបចំបញ្ជីវិភាគមុខងារ ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ដោយមានការពិគ្រោះយោបល់ជាមួយគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប.) នឹងមានមូលដ្ឋានរឹងមាំសម្រាប់ដំណាក់កាលក្រោយៗក្នុងការពិនិត្យមើលមុខងារឡើងវិញ និងអនុញ្ញាតឱ្យមានការពិចារណាអំពីមុខងារនានាសម្រាប់ធ្វើវិមជ្ឈការ និងវិសហមជ្ឈការ។ ជាការសំខាន់សម្រាប់ក្រសួងស្ថាប័ន ទាំងឡាយក្នុងការរៀបចំបញ្ជីវិភាគមុខងារឱ្យមានលក្ខណៈសមស្រប និងអាចប្រៀបធៀបបានដើម្បីជួយរាជរដ្ឋាភិបាលកម្ពុជាក្នុងការសម្រេចអំពីវិធីសាស្ត្រសមស្របក្នុងការធ្វើវិមជ្ឈការ និងវិសហមជ្ឈការនៃមុខងារនៅតាមវិស័យ ឬកិច្ចការ និងនៅតាមក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់។

គោលបំណងចម្បងនៃការរៀបចំបញ្ជីវិភាគមុខងារ គឺដើម្បីជាមូលដ្ឋានសម្រាប់ការពិនិត្យមើលមុខងារឡើងវិញរបស់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់។

ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ត្រូវមានភាពជាម្ចាស់លើការរៀបចំបញ្ជីវិភាគមុខងាររបស់ខ្លួន។

## ២. មូលដ្ឋាននៃសេចក្តីណែនាំ

សេចក្តីណែនាំនេះ ត្រូវបានរៀបចំឡើងដោយផ្អែកលើមូលដ្ឋានគតិយុត្ត និងក្របខ័ណ្ឌគោលនយោបាយដូចខាងក្រោម :

- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ច្បាប់ស្តីពីគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- អនុក្រឹត្យលេខ៦៨ អនក្រ.បក ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១២ ស្តីពីដំណើរទូទៅនៃការផ្ទេរមុខងារ និងធនធានឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
- កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិរយៈពេល១០ឆ្នាំ (២០១០-២០១៩)
- ផែនការអនុវត្តរយៈពេល៣ឆ្នាំដំបូង (២០១១-២០១៣)

ឯកសារគតិយុត្ត និងក្របខ័ណ្ឌគោលនយោបាយខាងលើតម្រូវឱ្យក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ដែលទទួលខុសត្រូវលើមុខងារស្ថិតនៅក្នុងចំណោមវិស័យ ឬកិច្ចការអាទិភាពត្រូវចាប់ផ្តើមរៀបចំបញ្ជីវិភាគមុខងារមុនក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ដែលមិនស្ថិតនៅក្នុងចំណោមវិស័យ ឬកិច្ចការអាទិភាព និងបញ្ចប់ឱ្យបានរួចរាល់តាមពេលវេលាដែលកំណត់ដោយសេចក្តីសម្រេចរបស់ គ.ជ.អ.ប.។ ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ដែលមិនស្ថិតនៅក្នុងចំណោមវិស័យ ឬកិច្ចការអាទិភាពក៏ត្រូវចាប់ផ្តើមរៀបចំបញ្ជីវិភាគមុខងារដែរទៅតាមពេលវេលាដែលកំណត់ដោយសេចក្តីសម្រេចរបស់ គ.ជ.អ.ប.។

## ៣. វិសាលភាពនៃសេចក្តីណែនាំ

សេចក្តីណែនាំនេះផ្តោតតែទៅលើការរៀបចំបញ្ជីវិភាគមុខងាររបស់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ប៉ុណ្ណោះ។ សេចក្តីណែនាំបន្ថែមមួយផ្សេងទៀតនឹងផ្តោតទៅលើការពិនិត្យមើលមុខងារឡើងវិញរបស់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់។

## ៤. វាក្យសព្ទបច្ចេកទេសដែលប្រើនៅក្នុងសេចក្តីណែនាំ

- **វិមជ្ឈការ** : រាជរដ្ឋាភិបាលកម្ពុជាផ្តល់ឱ្យក្រុមប្រឹក្សាថ្នាក់ក្រោមជាតិនូវភាពជាម្ចាស់លើមុខងារ សិទ្ធិអំណាច និងធនធានដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការក្នុងមូលដ្ឋាន។ ក្រុមប្រឹក្សាត្រូវមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋមូលដ្ឋានលើបញ្ហាទាំងនេះ។
- **វិសហមជ្ឈការ** : រាជរដ្ឋាភិបាលកម្ពុជា ឬក្រសួង ស្ថាប័នធ្វើប្រតិភូកម្មមុខងារ សិទ្ធិអំណាច និងធនធានទៅអង្គភាពក្រោមបង្គាប់ ឬទៅក្រុមប្រឹក្សាប្រភេទណាមួយដើម្បីអនុវត្តក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ឬក្រសួង ស្ថាប័ន។ អង្គភាព ឬក្រុមប្រឹក្សានោះត្រូវមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័នស្របតាមតម្រូវការនៃការធ្វើប្រតិភូកម្មនោះ។
- **មុខងារ** : សំដៅដល់អំពើ ឬសកម្មភាពដែលរាប់បញ្ចូលទាំងការផ្តល់សេវាសាធារណៈ ហេដ្ឋារចនាសម្ព័ន្ធ និងមធ្យោបាយផ្សេងទៀត។ មុខងារអាចត្រូវបានបែងចែកជាមុខងាររង។ ជាទូទៅមុខងារមានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធជាមួយនឹងមុខងាររង ដែលត្រូវបានចាត់ចូលក្នុងក្រុមជាមួយគ្នាក្រោមមុខងារនោះ។ ឧទាហរណ៍មុខងារនៃការសាងសង់ និងការថែទាំផ្លូវថ្នល់ អាចមានមុខងាររងនានាដូចមានបញ្ជាក់នៅក្នុងឧទាហរណ៍ខាងក្រោម។ ជាទូទៅ មុខងាររងអាចមានប្រភេទសកម្មភាពផ្សេងៗគ្នា ឧទាហរណ៍ (i).ការចាត់ចែង និងការគ្រប់គ្រង (ii).ការរៀបចំច្បាប់ ឬវិធានគតិយុត្ត (iii).ការធ្វើផែនការ ឬការលើកគម្រោង (iv).ការសាងសង់ ឬផលិតកម្ម (v).ប្រតិបត្តិការ និងការថែទាំ និង (vi). ការពិនិត្យតាមដាន និងការវាយតម្លៃ ជាដើម។

**ឧទាហរណ៍ : មុខងារ និងមុខងាររងសម្រាប់ផ្លូវថ្នល់**

| |
|---|
| **១. ការសាងសង់ និងការថែទាំផ្លូវថ្នល់**<br>**១.១. ការសាងសង់ និងការថែទាំផ្លូវលំជនបទ**<br>១.១.១. ការគ្រប់គ្រងចាត់ចែងផ្លូវលំជនបទ<br>១.១.២. ការរៀបចំវិធានគតិយុត្តសម្រាប់ផ្លូវលំជនបទ<br>១.១.៣. ការរៀបចំផែនការឬលើកគម្រោងផ្លូវលំជនបទថ្មីនិងការថែទាំ<br>១.១.៤. ការសាងសង់ និងការថែទាំផ្លូវលំជនបទ<br>១.១.៥. ការពិនិត្យតាមដាន និងវាយតម្លៃផ្លូវលំជនបទដែលមានស្រាប់<br>...<br>**១.២. ការសាងសង់ និងការថែទាំផ្លូវជាតិ**<br>១.២.១.<br>... |

- វាក្យសព្ទដទៃទៀត ពេលខ្លះត្រូវបានប្រើជំនួសឱ្យគ្នាទៅវិញទៅមកជាមួយនឹងពាក្យមុខងារ។ ពាក្យដែលត្រូវបានប្រើនៅក្នុងការពិភាក្សាអំពីមុខងាររបស់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់មានដូចជា (i).សកម្មភាពត្រូវបានអនុវត្ត (ii).ការទទួលខុសត្រូវត្រូវបានប្រគល់ ឬផ្ទេរប្រតិភូកម្ម និង (iii).កិច្ចការដែលក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់អនុវត្តដោយប្រើប្រាស់ធនធានរបស់ខ្លួន។

## ៥. ដំណើរការនៃរៀបចំបញ្ជីវិភាគមុខងារ

ក្រសួង ស្ថាប័នត្រូវមានភាពជាម្ចាស់ក្នុងដំណើរការរៀបចំបញ្ជីវិភាគមុខងារ និងត្រូវធានាឱ្យមានការចូលរួមពីគ្រប់កម្រិតនៃក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់។

ចំពោះក្រសួង ស្ថាប័នដែលបានកំពុងដំណើរការ ឬទើបបញ្ចប់ថ្មីៗនូវការរៀបចំបញ្ជីវិភាគមុខងារ ត្រូវពិនិត្យមើលឡើងវិញ និងកែសម្រួលឱ្យស្របតាមខ្លឹមសារនៃសេចក្តីណែនាំនេះ។

ដំណើរការរៀបចំបញ្ជីវិភាគមុខងាររបស់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់មាន ១០ជំហានដូចខាងក្រោម :

**ជំហានទី១** : ការរៀបចំ និងឯកភាពលើផែនការការងារសម្រាប់ការរៀបចំបញ្ជីវិភាគមុខងារ

**ជំហានទី២** : ការស្រង់មុខងារដែលមានកំណត់នៅក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា

**ជំហានទី៣** : ការពិនិត្យផ្ទៀងផ្ទាត់មុខងារដែលបានស្រង់ក្នុងជំហានទី២ជាមួយនឹងការអនុវត្តជាក់ស្តែង

**ជំហានទី៤** : ការពិនិត្យផ្ទៀងផ្ទាត់បន្ថែមលើមុខងារដែលមានកំណត់នៅក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាជាមួយនឹងផែនការ និងយុទ្ធសាស្ត្រសំខាន់ៗរយៈពេលមធ្យម

**ជំហានទី៥** : ការបូកសរុបព័ត៌មានដែលប្រមូលបាននៅក្នុងជំហានទី២ដល់ជំហានទី៤

**ជំហានទី៦** : ការប្រមូលព័ត៌មានអំពីការពង្រាយបុគ្គលិក និងផ្គូរផ្គងបុគ្គលិកទាំងនេះជាមួយនឹងមុខងារដែលកំណត់នៅក្នុងជំហានទី៥

**ជំហានទី៧** : ការប្រមូលព័ត៌មានអំពីការវិភាជហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល និងផ្គូរផ្គងធនធានហិរញ្ញវត្ថុទាំងនេះជាមួយនឹងមុខងារដែលកំណត់នៅក្នុងជំហានទី៥

**ជំហានទី៨** : ការប្រមូលព័ត៌មានអំពីការផ្តល់ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍ និងផ្គូរផ្គងធនធានហិរញ្ញវត្ថុទាំងនេះជាមួយនឹងមុខងារដែលបានកំណត់នៅក្នុងជំហានទី ៥

**ជំហានទី៩** : ការចងក្រងជាឯកសារនូវបទពិសោធន៍ពាក់ព័ន្ធនឹងវិមជ្ឈការនិងវិសហមជ្ឈការមុខងារ និងការចុះកិច្ចសន្យាជាមួយវិស័យឯកជន និងអង្គការសង្គមស៊ីវិល

**ជំហានទី១០** : ការរៀបចំរបាយការណ៍ស្តីពីការវិភាគមុខងារ និងទទួលការឯកភាពពីក្រសួងស្ថាប័នចំពោះរបាយការណ៍រៀបចំបញ្ជីវិភាគមុខងារចុងក្រោយមុនដាក់ជូន គ.ជ.អ.ប.

# ជំហានទី១
# ការរៀបចំ និងឯកភាពលើផែនការការងារនៃការរៀបចំបញ្ជីវិភាគមុខងារ

## ១.១. គោលបំណង

គោលបំណងសំខាន់នៃជំហានទី១នេះ គឺដើម្បីឱ្យក្រសួង ស្ថាប័នរៀបចំ និងឯកភាពលើផែនការការងារនៃការរៀបចំបញ្ជីវិភាគមុខងារ ដោយមានការសម្របសម្រួល និងជំនួយពីលេខាធិការដ្ឋាន គ.ជ.អ.ប.។

## ១.២. លទ្ធផលរំពឹងទុក

លទ្ធផលរំពឹងទុកក្នុងជំហាននេះ គឺផែនការការងារនៃការរៀបចំបញ្ជីវិភាគមុខងាររបស់ក្រសួង ស្ថាប័ននានាត្រូវបានរៀបចំឡើង។

តារាងគំរូទី១ : ផែនការការងារនៃការរៀបចំបញ្ជីវិភាគមុខងាររបស់ក្រសួង ស្ថាប័ន .................

| លរ | ជំហាន | សកម្មភាពលម្អិត | អ្នកទទួលខុសត្រូវ | កាលបរិច្ឆេទចាប់ផ្តើម និងបញ្ចប់ | ស្ថានភាពនៃការអនុវត្ត |
|---|---|---|---|---|---|
| ១. | រៀបចំ និងឯកភាពលើផែនការការងារសម្រាប់ការរៀបចំបញ្ជីវិភាគមុខងារ | | | | |
| ២. | ស្រង់មុខងារដែលមានកំណត់នៅក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា | | | | |
| ៣. | ពិនិត្យផ្ទៀងផ្ទាត់មុខងារដែលបានស្រង់ក្នុងជំហានទី២ជាមួយនឹងការអនុវត្តជាក់ស្តែង | | | | |
| ៤. | ពិនិត្យផ្ទៀតផ្ទាត់បន្ថែមលើមុខងារដែលមានកំណត់នៅក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាជាមួយនឹងផែនការ និងយុទ្ធសាស្ត្រសំខាន់ៗរយៈពេលមធ្យម | | | | |
| ៥. | បូកសរុបព័តិមានដែលប្រមូលបាននៅក្នុងជំហានទី២ដល់ទី៤ | | | | |
| ៦. | ប្រមូលព័តិមានអំពីការពង្រាយបុគ្គលិក និងផ្គូរផ្គងបុគ្គលិកទាំងនេះជាមួយនឹងមុខងារដែលកំណត់នៅក្នុងជំហានទី៥ | | | | |
| ៧. | ប្រមូលព័តិមានអំពីការវិភាជហិរញ្ញវត្ថុរបស់រដ្ឋាភិបាល និងផ្គូរផ្គងធនធានហិរញ្ញវត្ថុទាំងនេះជាមួយនឹងមុខងារគន្លឹះដែលកំណត់នៅក្នុងជំហានទី៥ | | | | |

| ល.រ | ជំហាន | សកម្មភាពលម្អិត | អ្នកទទួលខុសត្រូវ | កាលបរិច្ឆេទចាប់ផ្តើម និងបញ្ចប់ | ស្ថានភាពនៃការអនុវត្ត |
|---|---|---|---|---|---|
| ៨. | ប្រមូលព័ត៌មានអំពីការផ្តល់ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍ និងផ្លូវផ្តល់ធនធានហិរញ្ញវត្ថុទាំងនេះជាមួយនឹងមុខងារដែលកំណត់នៅក្នុងជំហានទី៥ | | | | |
| ៩. | ចងក្រងជាឯកសារនូវបទពិសោធន៍ពាក់ព័ន្ធនឹងវិមជ្ឈការនិងវិសហមជ្ឈការមុខងារ និងការចុះកិច្ចសន្យាជាមួយវិស័យឯកជន និងអង្គការសង្គមស៊ីវិល | | | | |
| ១០. | រៀបចំនិងឯកភាពលើរបាយការណ៍ដែលត្រូវដាក់ជូនគ.ជ.អ.ប.ដោយសង្ខេបព័ត៌មានដែលប្រមូលបាននៅក្នុងជំហានទី១ដល់ទី៩ | | | | |

## ១.៣. ដំណើរការ

សកម្មភាពសំខាន់ៗដើម្បីអនុវត្តជំហានទី១ មានដូចខាងក្រោម ៖

១. **ការជូនដំណឹងពី គ.ជ.អ.ប. ដល់ក្រសួង ស្ថាប័ន** ៖ គ.ជ.អ.ប. ត្រូវជូនដំណឹងដល់ក្រសួង ស្ថាប័នអំពីការចាប់ផ្តើមការរៀបចំបញ្ជីវិភាគមុខងារ ព្រមទាំងបញ្ជាក់អំពីលទ្ធភាពនៃការគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុពីលេខាធិការដ្ឋាន គ.ជ.អ.ប ដល់ក្រសួង ស្ថាប័នទាំងនោះ ស្របតាមលក្ខខណ្ឌតម្រូវដោយអនុក្រឹត្យលេខ៦៨ អនក្រ.បក ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១២ស្តីពីដំណើរការទូទៅនៃការផ្ទេរមុខងារ និងធនធានឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ និងសេចក្តីសម្រេចរបស់ គ.ជ.អ.ប. (ឧទាហរណ៍ សិក្ខាសាលាអំពីសាវតានៃកំណែទម្រង់ ឯកសារបណ្តុះបណ្តាល និងការផ្តល់ទីប្រឹក្សាបច្ចេកទេស ។ល ។) ។

២. **ការយល់ព្រមរបស់ក្រសួង ស្ថាប័ន** ៖ ថ្នាក់ដឹកនាំរបស់ក្រសួង ស្ថាប័ន (រដ្ឋមន្ត្រី ឬប្រធានស្ថាប័ន) ត្រូវជូនដំណឹងអំពីការយល់ព្រមនេះមក គ.ជ.អ.ប. រួមជាមួយបញ្ជីឈ្មោះជនបង្គោលរបស់ក្រសួង ស្ថាប័នដែលត្រូវបានតែងតាំងសម្រាប់ការរៀបចំបញ្ជីវិភាគមុខងារ ដែលជាធម្មតា គឺជាប្រធានក្រុមការងារវិមជ្ឈការ និង វិសហមជ្ឈការរបស់ក្រសួង ស្ថាប័ន រួមនឹងថ្នាក់ដឹកនាំ ឬមន្ត្រីដទៃទៀតដែលត្រូវបំពេញកិច្ចការនេះ ។

៣. **ការកោះប្រជុំក្រុមការងារវិមជ្ឈការ និងវិសហមជ្ឈការ** ៖ ប្រធានក្រុមការងារវិមជ្ឈការ និងវិសហមជ្ឈការរបស់ក្រសួង ស្ថាប័ន ត្រូវកោះប្រជុំក្រុមការងាររបស់ខ្លួនដើម្បីពិនិត្យ និងពិភាក្សាលើគោលបំណងនៃការរៀបចំបញ្ជីវិភាគមុខងារ និងកិច្ចការដែលពាក់ព័ន្ធ ។

៤. **ការបង្កើតក្រុមការងារបច្ចេកទេស** ៖ ក្រុមការងារវិមជ្ឈការ និងវិសហមជ្ឈការរបស់ក្រសួង ស្ថាប័នត្រូវ

បង្កើតក្រុមការងារបច្ចេកទេសមួយពីសមាជិករបស់ខ្លួន ដើម្បីសម្របសម្រួលរាល់ដំណាក់កាលទាំងអស់នៃការរៀបចំបញ្ជីវិភាគមុខងារ។ ក្រុមការងារវិមជ្ឈការ និងវិសហមជ្ឈការត្រូវធានាថា ក្រុមការងារបច្ចេកទេសមានសមត្ថភាព ជំនាញ និងសមភាពយេនឌ័រ ។ល ។ ដើម្បីអនុវត្តការងាររៀបចំបញ្ជីវិភាគមុខងារឱ្យបានត្រឹមត្រូវ ។

៥. **ការកំណត់ពីតម្រូវការនៃជំនួយបច្ចេកទេស :** ក្រុមការងារវិមជ្ឈការ និងវិសហមជ្ឈការរបស់ក្រសួង ស្ថាប័ន ត្រូវកំណត់អំពីទីប្រឹក្សាបច្ចេកទេសដែលចាំបាច់ដោយពិគ្រោះយោបល់ជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប. ប្រសិនបើយល់ឃើញថា តម្រូវការបច្ចេកទេស គឺជាការចាំបាច់ដើម្បីអនុវត្តការរៀបចំបញ្ជីវិភាគមុខងារ។ លេខាធិការដ្ឋាន គ.ជ.អ.ប. នឹងជួយប្រសិនបើអាចធ្វើទៅបាន (i).ក្នុងការបង្កើតលក្ខខណ្ឌការងារសមស្រប និងកំណត់ពីទីប្រឹក្សាបច្ចេកទេស និងហិរញ្ញវត្ថុដើម្បីជួយដល់ការងាររៀបចំបញ្ជីវិភាគមុខងារ និង (ii).សម្របសម្រួលជំនួយហិរញ្ញវត្ថុរបស់ដៃគូអភិវឌ្ឍន៍ដែលពាក់ព័ន្ធ។

៦. **ការរៀបចំផែនការការងារ :** ក្រុមការងារបច្ចេកទេសត្រូវកំណត់អំពីសកម្មភាពលម្អិត អ្នកទទួលខុសត្រូវ និងកាលបរិច្ឆេទសម្រាប់ការចាប់ផ្ដើម និងការបញ្ចប់នៃជំហាននីមួយៗនៃការរៀបចំបញ្ជីវិភាគមុខងារ។ ផែនការការងារត្រូវរៀបចំតាមតារាងគំរូទី១ខាងលើ ។

៧. **ការកំណត់កាលវិភាគសម្រាប់ពិគ្រោះយោបល់ជាមួយអង្គភាពនានារបស់ក្រសួង ស្ថាប័ននៅថ្នាក់ជាតិ :** ក្រុមការងារបច្ចេកទេសត្រូវកំណត់អង្គភាព ថ្នាក់ដឹកនាំ និងមន្ត្រីសំខាន់ៗ(ដោយគិតពីតុល្យភាពយេនឌ័រ) សម្រាប់ការចូលរួមនៅក្នុងការអង្កេត និង ឬការសម្ភាសន៍ និងរៀបចំកាលវិភាគសម្រាប់កិច្ចប្រជុំផ្ទៃក្នុងព្រមទាំងជូនដំណឹងជាមុនអំពីដំណើរការនៃការសិក្សានេះ។

៨. **ការរៀបចំផែនការសកម្មភាពដើម្បីពិគ្រោះយោបល់នៅមូលដ្ឋាន :** ក្រុមការងារបច្ចេកទេសត្រូវរៀបចំសកម្មភាព កាលវិភាគ និងកំណត់មន្ត្រីសំខាន់ៗនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិរបស់ក្រសួង ស្ថាប័នដែលត្រូវចុះធ្វើការសិក្សានៅមូលដ្ឋាន។

៩. **ការរៀបចំផែនការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធដទៃទៀត :** ក្រុមការងារបច្ចេកទេសត្រូវរៀបចំសកម្មភាព កាលវិភាគ និងកំណត់អ្នកពាក់ព័ន្ធសំខាន់ៗដទៃទៀតដូចជា អង្គការមិនមែនរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ដែលធ្វើការជាមួយក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់សម្រាប់ការពិគ្រោះយោបល់តាមការចាំបាច់ ។

១០. **ការពិនិត្យ និងឯកភាពលើផែនការការងារ :** បន្ទាប់ពីរៀបចំសេចក្ដីព្រាងផែនការការងារខាងលើរួច ក្រុមការងារបច្ចេកទេសត្រូវបញ្ជូនសេចក្ដីព្រាងនេះមកក្រុមការងារវិមជ្ឈការ និងវិសហមជ្ឈការដើម្បីដាក់សេចក្ដីព្រាងនេះជូនថ្នាក់ដឹកនាំក្រសួង ស្ថាប័នពិនិត្យ និងសម្រេច។ បន្ទាប់ពីទទួលបានការឯកភាពពីថ្នាក់ដឹកនាំក្រសួង ស្ថាប័ន ក្រុមការងារវិមជ្ឈការ និងវិសហមជ្ឈការត្រូវធ្វើការបែងចែកផែនការការងារដល់អ្នកពាក់ព័ន្ធទាំងអស់ និងចាប់ផ្ដើមអនុវត្តផែនការការងារនេះភ្លាម ។

# ជំហានទី២
# ការស្រង់មុខងារដែលមានកំណត់នៅក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា

## ២.១. គោលបំណង

គោលបំណងចម្បងនៃជំហានទី២ គឺរៀបចំបញ្ជីលម្អិតនៃមុខងាររបស់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ដែលមានចែងក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាដែលនៅជាធរមាន។

## ២.២. លទ្ធផលរំពឹងទុក

លទ្ធផលរំពឹងទុកក្នុងជំហាននេះ គឺបញ្ជីលម្អិតនៃមុខងាររបស់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដែលមានចែងក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ត្រូវបានរៀបចំឡើង។

តារាងគំរូទី ២ :បញ្ជីលម្អិតនៃមុខងាររបស់ក្រសួង ស្ថាប័ន .................................

| មុខងារ | លិខិតបទដ្ឋានគតិយុត្តយោង | ស្ថាប័នអនុវត្ត | | | |
|---|---|---|---|---|---|
| | | ទីស្តីការក្រសួង | មន្ទីរ អង្គភាពខេត្ត | ការិយាល័យ ក្រុង ស្រុក ខណ្ឌ | ផ្សេងទៀត (បើមាន) |
| **មុខងារទី១.............................** | | | | | |
| មុខងាររងទី១.១ | | | | | |
| មុខងាររងទី១.២. | | | | | |
| មុខងាររងទី... | | | | | |
| **មុខងារទី២.............................** | | | | | |
| មុខងាររងទី២.១. | | | | | |
| មុខងាររងទី២.២. | | | | | |
| មុខងាររងទី... | | | | | |
| **មុខងារទី៣.............................** | | | | | |
| មុខងាររងទី៣.១. | | | | | |
| មុខងាររងទី៣.២. | | | | | |
| មុខងាររងទី... | | | | | |

## ២.៣. ដំណើរការ

សកម្មភាពសំខាន់ៗដើម្បីអនុវត្តជំហានទី២ មានដូចខាងក្រោម :

**១. ការប្រមូលឯកសារច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា និងទិន្នន័យដែលពាក់ព័ន្ធនឹងមុខងាររបស់ក្រសួង ស្ថាប័ន :** ក្រុមការងារបច្ចេកទេសរបស់ក្រសួង ស្ថាប័ននីមួយៗត្រូវប្រមូលឯកសារច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា និងទិន្នន័យដែលពាក់ព័ន្ធនឹងមុខងាររបស់ក្រសួង ស្ថាប័ន។ មូលដ្ឋានទិន្នន័យដ៏សំខាន់ដែលអាចយកមកប្រើ

ប្រាស់បានគឺទិន្នន័យស្តីពីសិទ្ធិអំណាច និងមុខងាររបស់រាជរដ្ឋាភិបាលកម្ពុជា ដែលអាចរកបានជាឯកសារអេឡិចត្រូនិកតាមរយៈលេខាធិការដ្ឋាន គ.ជ.អ.ប.។ ទិន្នន័យនេះមានសារៈប្រយោជន៍សម្រាប់ក្រសួង ស្ថាប័ននីមួយៗក្នុងការចាប់ផ្តើមរៀបចំបញ្ជីមុខងាររបស់ខ្លួន ដោយសារទិន្នន័យនេះមានព័ត៌មានដែលបានវិភាគរួចហើយនៅក្នុងក្របខ័ណ្ឌមុខងារដែលធ្វើឱ្យមានភាពងាយស្រួល ក្នុងការបែងចែកជាក្រុម និងការធ្វើបញ្ជីមុខងារ និងមុខងាររងនៅក្នុងក្របខ័ណ្ឌមុខងារដែលមានលក្ខណៈស៊ីសង្វាក់គ្នា។

២. **ការស្រង់មុខងារដែលមានកំណត់នៅក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា :** ក្រុមការងារបច្ចេកទេសរបស់ក្រសួង ស្ថាប័ននីមួយៗត្រូវធ្វើការស្រង់មុខងារ និងមុខងាររងទាំងអស់ដែលមានកំណត់នៅក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដែលក្រសួង ស្ថាប័នមានដូចជា ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស ឬលិខិតបទដ្ឋានគតិយុត្តនានាចូលទៅក្នុងតារាងគំរូទី២។ ពាក់ព័ន្ធនឹងការស្រង់មុខងារនេះ ក្រុមការងារបច្ចេកទេសរបស់ក្រសួង ស្ថាប័នអាចប្រើប្រាស់ទិន្នន័យស្តីពីសិទ្ធិអំណាច និងមុខងាររបស់រាជរដ្ឋាភិបាលកម្ពុជាជាមូលដ្ឋានក្នុងការស្រង់បញ្ចូលទៅក្នុងតារាងគំរូទី២រួចហើយត្រូវធ្វើការផ្ទៀងផ្ទាត់ជាមួយនឹងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនឹងមុខងាររបស់ក្រសួង ស្ថាប័ន។

៣. **ការប្រជុំពិនិត្យ ផ្ទៀងផ្ទាត់បញ្ជីមុខងារដែលបានស្រង់ :** បន្ទាប់ពីបានស្រង់នូវមុខងារដែលបានកំណត់នៅក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានារួចហើយក្រុមការងារវិមជ្ឈការ និងវិសហមជ្ឈការរបស់ក្រសួង ស្ថាប័ននីមួយៗ ត្រូវរៀបចំកិច្ចប្រជុំផ្ទៃក្នុងមួយដើម្បីពិនិត្យ ផ្ទៀងផ្ទាត់លើបញ្ជីមុខងារដែលបានស្រង់។

# ជំហានទី៣

# ការពិនិត្យផ្ទៀងផ្ទាត់មុខងារដែលបានស្រង់ក្នុងជំហានទី២ជាមួយនឹងការអនុវត្តជាក់ស្តែង

## ៣.១. គោលបំណង

គោលបំណងចម្បងនៃជំហានទី៣ គឺពិនិត្យផ្ទៀងផ្ទាត់មុខងាររបស់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដែលមានចែងក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាជាមួយនឹងមុខងារដែលកំពុងអនុវត្តជាក់ស្តែងតាមរយៈការពិគ្រោះយោបល់ផ្ទៃក្នុង។

## ៣.២. លទ្ធផលរំពឹងទុក

លទ្ធផលរំពឹងទុកក្នុងជំហាននេះ គឺការរកឃើញពីភាពខុសគ្នារវាងមុខងារដែលកំពុងអនុវត្តជាក់ស្តែងដោយក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ជាមួយនឹងមុខងារដែលកំណត់ដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា។ ភាពខុសគ្នានេះរួមមានស្ថានភាពនៃមុខងារដែលកំណត់ដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ប៉ុន្តែមិនត្រូវបានអនុវត្តជាក់ស្តែង និងស្ថានភាពនៃមុខងារមួយចំនួនដែលកំពុងអនុវត្តជាក់ស្តែង ប៉ុន្តែមិនមានចែងនៅក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត។ ផ្អែកលើការរកឃើញពីភាពខុសគ្នានេះ អាចនាំឱ្យមានការបន្ថែមមុខងារ ឬការដកមុខងារចេញពីមុខងារដែលកំណត់ក្នុងលិខិតបទដ្ឋានគតិយុត្តដែលមាននៅក្នុងតារាងទី២។

## ៣.៣. ដំណើរការ

សកម្មភាពសំខាន់ៗដើម្បីអនុវត្តជំហានទី៣មានដូចខាងក្រោម :

១. **ការចងក្រង និងធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់** ក្រុមការងារបច្ចេកទេសរបស់ក្រសួង ស្ថាប័ន ត្រូវចងក្រង និងធ្វើបច្ចុប្បន្នភាពនូវរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ដែលបានកំណត់ដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាជាមួយនឹងរចនាសម្ព័ន្ធដែលមានជាក់ស្តែង រួមទាំងរចនាសម្ព័ន្ធដែលបានរៀបចំឡើងសម្រាប់គាំទ្រដល់ការអនុវត្តគម្រោង ឬកម្មវិធីនានាដែលគាំទ្រដោយដៃគូអភិវឌ្ឍន៍។

២. **ការកំណត់អង្គភាពដែលមាននៅក្នុងរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ដើម្បីធ្វើការពិគ្រោះយោបល់** ផ្អែកលើរចនាសម្ព័ន្ធដែលបានចងក្រង និងធ្វើបច្ចុប្បន្នភាពខាងលើ ក្រុមការងារបច្ចេកទេសរបស់ក្រសួង ស្ថាប័ន ត្រូវកំណត់អំពីអង្គភាពមួយចំនួន ឬទាំងអស់របស់ក្រសួង ស្ថាប័ន មន្ទីរ ការិយាល័យ អង្គភាពនានា និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់មន្ត្រីពាក់ព័ន្ធសំខាន់ៗ ព្រមទាំងអង្គការសហគមន៍មូលដ្ឋានដែលក្រសួង ស្ថាប័នមានភ្នាក់ងារ ឬតំណាងដែលត្រូវបានធ្វើប្រតិភូកម្មឱ្យបំពេញភារកិច្ចរបស់ខ្លួននៅថ្នាក់ក្រោមជាតិ (ឧទាហរណ៍ ក្រុមកសិករអ្នកប្រើប្រាស់ទឹក សហគមន៍នេសាទ សហគមន៍ព្រៃឈើ និងក្រុមអភិវឌ្ឍន៍ភូមិ ជាដើម) ដើម្បីធ្វើការពិគ្រោះយោបល់។ ការកំណត់អ្នកចូលរួមខាងលើនេះ ត្រូវធានាឱ្យមានសមភាពយេនឌ័រ។

៣. **ការពិគ្រោះយោបល់** ក្រុមការងារបច្ចេកទេសរបស់ក្រសួង ស្ថាប័ន ត្រូវរៀបចំការពិគ្រោះយោបល់ជាមួយអង្គភាព និងអ្នកពាក់ព័ន្ធដែលបានកំណត់ខាងលើ ។

ការពិគ្រោះយោបល់អាចធ្វើតាមវិធីសាស្ត្រមួយចំនួនដូចខាងក្រោម :

- **សិក្ខាសាលា :** សិក្ខាសាលានេះអាចជាសិក្ខាសាលារួមមួយ ដោយប្រមូលផ្តុំអង្គភាពសំខាន់ៗ និងអ្នកពាក់ព័ន្ធទាំងអស់នៅពេលតែមួយ ឬជាសិក្ខាសាលាដាច់ដោយឡែកដោយប្រមូលផ្តុំប្រភេទគ្រប់គ្រង ស្រដៀងគ្នា ឧទាហរណ៍ (i).ប្រភេទរដ្ឋបាល ហិរញ្ញវត្ថុ (ii).ប្រភេទអ្នកតាក់តែងគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្ត (iii).ប្រភេទអ្នកបច្ចេកទេស (iv).មន្ទីរ អង្គភាពថ្នាក់រាជធានី ខេត្ត និង (v).ការិយាល័យក្រុង ស្រុក ខណ្ឌ ។ល។
- **កិច្ចពិភាក្សាក្រុមតូច :** កិច្ចពិភាក្សាទាំងនេះគួរផ្តោតជាសំខាន់លើមន្ទីរ ឬការិយាល័យ ឬក្រុមមន្ត្រីជាក់លាក់ណាមួយ ។
- **ការរៀបចំ និងការបំពេញបញ្ជីសំណួរជាលាយលក្ខណ៍អក្សរ :** ក្រុមការងារបច្ចេកទេសរបស់ក្រសួង ស្ថាប័ន ត្រូវរៀបចំបញ្ជីសំណួរគន្លឹះដើម្បីផ្ញើជូនមន្ទីរ អង្គភាព ការិយាល័យ និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ព្រមទាំងភ្នាក់ងារពាក់ព័ន្ធសំខាន់ៗដើម្បីបំពេញ ។ ចម្លើយដែលទទួលបាននឹងត្រូវពិនិត្យ និងវិភាគដោយក្រុមការងារបច្ចេកទេស ។

ឧទាហរណ៍អំពីសំណួរគន្លឹះសម្រាប់ការពិគ្រោះយោបល់ជាមួយអង្គភាពនានា

១. តើអង្គភាពដែលត្រូវពិគ្រោះយោបល់មានឈ្មោះអ្វី និងមានទីតាំងនៅទីណា?
២. តើលិខិតបទដ្ឋានគតិយុត្តសំខាន់ៗអ្វីខ្លះ (ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស ។ល ។) ដែលកំណត់ពីការងាររបស់អង្គភាពទាំងនេះ?
៣. តើមានឯកសាររដ្ឋបាលសំខាន់ៗអ្វីខ្លះក្រៅពីលិខិតបទដ្ឋានគតិយុត្ត ដែលកំណត់អំពីការងាររបស់អង្គភាព?
៤. តើមុខងារអ្វីខ្លះដែលអនុវត្តដោយអង្គភាពទាំងនេះ? ចូររាយឈ្មោះមុខងារទាំងនេះ និងកំណត់កម្រិតនៃសារៈសំខាន់ទាក់ទងនឹងពេលវេលា និងធនធានដែលប្រើប្រាស់សម្រាប់មុខងារទាំងនេះ (ពី ១ ដល់ ៥)? (១=មានសារសំខាន់ខ្លាំង ៥=មិនសូវមានសារសំខាន់)
